00640936 E9/3

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| ឯកសារទទួល |
| --- |
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 01 / 2011 |
| ម៉ោង (Time/Heure): 15:30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun |

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក-អជសដ

ភាគីដាក់ឯកសារ៖ សហមេធាវីការពារក្តីលោក អៀង សារី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **អង់គ្លេស**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ ០០២ ដោយអនុវត្តតាម**
**វិសោធនកម្មនីតិវិធីដែលបានស្នើសុំ និង**
**សំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ**

---

E9/3

| | |
|---|---|
| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ |
| **សហមេធាវីការពារក្តី** | **អង្គជំនុំជម្រះសាលាដំបូង** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រមបម្រុង យូរ ឧត្តរា |
| | ចៅក្រមបម្រុង Claudia FENZ |
| | |
| | **សហព្រះរាជអាជ្ញា** |
| | លោកស្រី ជា លាង |
| | លោក Andrew CAYLEY |
| | **ក្រុមមេធាវីការពារក្តីទាំងអស់** |

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“ក្រុមមេធាវីការពារក្តី”) សូមដាក់សំណើសុំឱ្យមានការកែប្រែការដឹកនាំនីតិវិធីជំនុំជម្រះនៅ អ.វ.ត.ក និងការផ្អាកលើដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ (“ដីកាបង្គាប់”)[1] ។ សំណើសុំនេះធ្វើឡើងដោយចាំបាច់ដោយហេតុថា វិធានផ្ទៃក្នុង (“វិធាន”) ចែងអំពីបែបបទនីតិវិធីជំនុំជម្រះ ដែលមានលក្ខណៈខុសពីបែបបទនីតិវិធីជំនុំជម្រះអនុវត្តនៅតាមបណ្តាតុលាការសាមញ្ញរបស់ប្រទេសកម្ពុជា។ ចំណុចគួរកត់សម្គាល់បំផុតនោះគឺ ក. ក.ស.ព ត្រូវមានបន្ទុកនៅក្នុងការបង្ហាញឱ្យអស់ពីវិមតិសង្ស័យ[2] និង ខ. កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក គោរព “គោលការណ៍ចំពោះមុខ”។ នៅពេលទទួលយកបែបបទទាំងនេះអ.វ.ត.ក[3] ហាក់ដូចជាមានបំណងងាកចេញពីនីតិវិធីព្រហ្មទណ្ឌដែលការសួរដេញដោលដឹកនាំដោយចៅក្រម ហើយបែរជាណែនាំនីតិវិធីសួរដេញដោលដោយគូភាគី ដែលជានីតិវិធីមានលក្ខណៈស្រដៀង នឹងនីតិវិធីអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (“តុលាការ ICC”) និងនៅតាមបណ្តាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍* ទាំងឡាយ[4]។ នីតិវិធីដែលបានប្រើប្រាស់នៅក្នុងសំណុំរឿងលេខ ០០១ និងនៅក្នុងតុលាការសាមញ្ញរបស់ប្រទេសកម្ពុជា មិនអាចអនុវត្តបាននៅក្នុងសំណុំរឿងលេខ ០០២ ឡើយ ដោយសារនីតិវិធីទាំងនេះនឹង៖ ក. បង្វែរបន្ទុកនៃការបង្ហាញភស្តុតាងពី ក.ស.ព ដោយរំលោភបំពានលើវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ ខ. រំលោភសិទ្ធិសច្ចធារណ៍និរទោសរបស់លោក អៀង សារី។ គ. រំលោភបុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯងរបស់លោក អៀង សារី ឬ បដិសេធមិនឱ្យលោក អៀង សារី ទទួលបានសម្ភារៈ/មធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តីរបស់គាត់។ និង ឃ. នាំឱ្យមានវិសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីរវាងក្រុមមេធាវីការពារក្តី និង ក.ស.ព។ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យទទួលយកវិសោធនកម្មនីតិវិធីដែលបានស្នើសុំ

---

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ ដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ចុះថ្ងៃទី ១៧ មករា ២០១១ ឯកសារលេខ E9, ERN: 00635754-00635759។

[2] ទោះបីជាសំណៅជាភាសាបារាំងនៃវិធាន៨៧(១) របស់វិធានផ្ទៃក្នុងចែងថា៖ “អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ” ជាជាងគ្រាន់តែការផ្តន្ទាទោសហួសពីវិមតិសង្ស័យ (ការបកប្រែក្រៅផ្លូវការ)។

[3] វិធានទាំងនោះត្រូវបានអនុម័ត និងត្រូវបានធ្វើវិសោធនកម្មតាមរយៈកិច្ចប្រជុំពេញអង្គ។ *សូមមើល* វិធាន១-៣ នៃវិធានផ្ទៃក្នុង។

[4] ឧទាហរណ៍ នៅពេលកិច្ចប្រជុំពេញអង្គនាខែកញ្ញា ឆ្នាំ២០១០ ចៅក្រម អ.វ.ត.ក បានអនុម័តធ្វើវិសោធនកម្មមួយនៅក្នុងវិធាន៩០ ដោយចៅក្រមបានលុបពាក្យ “ក្រោយពីចៅក្រមសួរចម្លើយរួចហើយ” ចេញពីមុខឃ្លា “សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវីក៏មានសិទ្ធិសួរជនជាប់ចោទផងដែរ”។

ដែលបានដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ។ អានុភាពនៃដីកាបង្គាប់ ដែលបានអនុវត្តចំពោះលោក អៀង សារី ត្រូវផ្អាកជាបន្ទាន់ ដោយហេតុថា ការអនុវត្តវិធាន ៨០(២) និងវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ("វិធាន ៨០") នៅមុនពេលមានការបង្ហាញរឿងក្តី ទាំងមូលប្រឆាំងនឹងលោក អៀង សារី នឹងជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់គាត់។ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យបើកសវនាការដេញដោលលើវិសោធនកម្មនីតិវិធីដែលបានស្នើសុំ។

## I. សាវតារ

១. កាលពីថ្ងៃទី ២៤ មករា ២០១១ ក្រុមមេធាវីការពារក្តី បានស្នើសុំដាក់សំណើសុំនេះជាភាសាអង់គ្លេសជាបឋមសិន រួចសឹមដាក់ភាសាខ្មែរតាមក្រោយ ("សំណើសុំអនុញ្ញាតដាក់មួយភាសាសិន")។ សំណើសុំអនុញ្ញាតដាក់មួយភាសាសិន ត្រូវបានឡើងជាចាំបាច់ ដោយហេតុថាដីកាបង្គាប់ តម្រូវអោយលោក អៀង សារី ផ្តល់នូវសម្ភារៈភស្តុតាងមួយចំនួន ដែលមានចែងក្នុងវិធាន ៨០(២) និង ៨០(៣) ("សម្ភារៈភស្តុតាងស្របតាមវិធាន ៨០") ក្នុងរយៈពេល ៣០ថ្ងៃ[5] ។ ពាក្យសុំនេះទាក់ទងដោយផ្ទាល់នឹងការអនុវត្តវិធាន ៨០ ចំពោះលោក អៀង សារី ។ សំណើសុំអនុញ្ញាតដាក់មួយភាសាសិន នឹងធ្វើអោយក្រុមមេធាវីការពារក្តីសន្សំសំចៃពេលវេលាបាន ៤ថ្ងៃ ដែលនឹងត្រូវបាត់បង់ដោយសារការបកប្រែ។ ដើម្បីរក្សានូវកាតព្វកិច្ចវីរិយភាព ក្រុមមេធាវីការពារក្តី បានដាក់នូវសំណើសុំនេះភ្លាមៗតាមដែលអាចធ្វើទៅបានបន្ទាប់ពីមានដីកាបង្គាប់មក។

២. នៅថ្ងៃទី ២៨ មករា ២០១១ គឺ ៤ ថ្ងៃបន្ទាប់ពីក្រុមមេធាវីការពារក្តីបានប៉ុនប៉ងដាក់សំណើសុំអនុញ្ញាតដាក់មួយភាសាសិន អង្គជំនុំជម្រះសាលាដំបូង បានបញ្ជូនត្រឡប់មកវិញនូវសំណើសុំដោយសារមូលហេតុការដាក់ឯកសារមិនគ្រប់គ្រាន់។ ហេតុផលដែលបានលើកឡើងនោះគឺថា សំណើសុំនេះមិនបានធ្វើស្របទៅតាមវិធាន ៧.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ព្រោះថាវាមិនត្រូវបានដាក់ជាមួយគ្នានូវភាសាខ្មែរ[6]។

---

[5] ដីកាបង្គាប់ កថាខណ្ឌ ២។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ ការជូនដំណឹងស្តីពីការដាក់ឯកសារមិនគ្រប់គ្រាន់សម្រាប់ សំណើរបស់ អៀង សារី សុំអនុញ្ញាតដាក់ជាភាសាអង់គ្លេសជាបឋមសិន រួចសឹមដាក់ឯកសារបកប្រែជាភាសាខ្មែរតាម

## II. ច្បាប់ពាក់ព័ន្ធ

### ក. បន្ទុកនៃការបង្ហាញភស្តុតាង

៣. វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ "សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

### ខ. កិច្ចដំណើរការនីតិវិធីចំពោះមុខ

៤. វិធាន ២១(១)(ក)នៃវិធានផ្ទៃក្នុងចែងថា៖ "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិ របស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស"[7]។

### គ. សច្ចធារណ៍និរទោស

៥. ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សមិនមានទោស ដរាបណាតុលាការមិនទាន់កាត់ទោស

---

ក្រោយ និងសំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ចុះថ្ងៃទី ២៨ មករា ២០១១។

[7] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/(អ.ប.ជ ៧១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4, ERN: 00601705-00601717, កថាខណ្ឌ១៦ ដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា៖ "...សហចៅក្រមស៊ើបអង្កេតត្រូវគោរពតាមវិធាន ២១(១)(ក) និងវិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង ដែលបានចែងថា ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ..."។

ជាស្ថាពរ[8]។

**ឃ. បុព្វសិទ្ធិមិនឆ្លើយប្រឆាំងនឹងខ្លួនឯង**

៦. មាត្រា ៣៥ ថ្មី(ឆ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ “នៅក្នុងការចោទប្រកាន់មកលើខ្លួនជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា...មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬ បង្ខំឱ្យឆ្លើយសារភាពថាមានកំហុស”[9]។

**ង. សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី**

៧. អនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អ.វ.ត.ក ត្រូវធានាថា ការជំនុំជម្រះ “ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ...ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”[10]។ មាត្រានេះកំណត់ថា

---

[8] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា: “ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។” មាត្រា៣៥ថ្មី នៃច្បាប់អ.វ.ត.ក ចែងថា: “ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។” វិធាន២១(១)(ឃ) ចែងនៅក្នុងផ្នែកដែលទាក់ទងថា: “ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណា ពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។” មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ចែងថា: “ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។” មាត្រា១១(១)នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស(“UDHR”) ចែងថា: “ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទ។”

[9] មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា: “ក្នុងការសម្រេចការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើជនណាមួយ ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ... មិនត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពថាមានពិរុទ្ធភាព។

[10] គូសបញ្ជាក់បន្ថែម។

អ.វ.ត.ក ត្រូវអនុវត្តយុត្តាធិការ "ឱ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពយុត្តិធម៌ និងដំណើរការត្រឹមត្រូវតាមច្បាប់ ដូចមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃ[កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ] ចុះឆ្នាំ១៩៦៦"។

៨. អនុលោមតាមវិធាន ២១(១)(ក)នៃវិធានផ្ទៃក្នុង "កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[11]។ សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ រួមទាំង សិទ្ធិ សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។ សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី គឺជា "គោលការណ៍ច្បាប់ ដែលកំណត់ថានៅក្នុងការជំនុំជម្រះ ក្រុមមេធាវីការពារក្តី និងស្ថាប័នអយ្យការ ត្រូវមានសមភាពខាងនីតិវិធីដើម្បីធានាយ៉ាងណាឱ្យកិច្ចដំណើរការនីតិវិធីរបស់តុលាការមានភាពយុត្តិធម៌"[12]។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ ០០១ បានបញ្ជាក់ថា "លក្ខណៈជាសារវ័ន្តនៃគោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង..."[13]។ គោលការណ៍នេះគឺជាគ្រឹះនៃលិខិតុបករណ៍អន្តរជាតិទាំងឡាយលើបញ្ហាសិទ្ធិមនុស្ស[14] ដែល អ.វ.ត.ត ត្រូវតែគោរពជាដាច់ខាត តាមស្មារតីនៃរដ្ឋធម្មនុញ្ញ

---

[11] គូសបញ្ជាក់បន្ថែម។

[12] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D288/6.90, ERN: 00345178-00345180, កថាខណ្ឌ៤។

[13] *ដូចដើងទំព័រខាងលើ។*

[14] យោងតាមមាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ: "ជនគ្រប់រូបត្រូវមាន ភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ដើម្បីសម្រេច លើការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងមកលើជនណាមួយ ឬដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ចក្នុងការដាក់បណ្តឹងតាមផ្លូវច្បាប់ ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ដែលបង្កើតឡើងដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងឥតលំអៀង"។ មាត្រា១០ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ចែងថា: "មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងឥតលំអៀងពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយយុត្តិធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌលើជននោះ។" (គូសបញ្ជាក់បន្ថែម)។

កម្ពុជា[15]។

### ច. សម្ភារៈ/មធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តី

៩. មាត្រា ៣៥ថ្មី(ខ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា...មានពេលវេលាដើម្បីរៀបចំខ្លួន និង ទាក់ទងជាមួយមេធាវីរបស់ខ្លួន"[16]។

### ជ. ការផ្អាកកិច្ចដំណើរការនីតិវិធី

១០. ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាំងវិធានផ្ទៃក្នុង មិនបានចែងអំពីលក្ខខណ្ឌចាំបាច់ នៅក្នុងការផ្អាក កិច្ចដំណើរការនីតិវិធីឡើយ។ ទោះបីជាយ៉ាងនេះក្តី ក.ស.ច.ស បានលើកឡើងថា ខ្លួន "យល់ឃើញថា គោលការណ៍ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ដែលត្រូវអនុវត្តចំពោះពាក្យបណ្តឹងសុំមោឃភាព និង ពាក្យបណ្តឹងសុំផ្អាកនីតិវិធី គឺជាគោលការណ៍តែមួយ ដោយសារថា សំណើសុំទាំងពីរប្រភេទនេះ ត្រូវបានធ្វើឡើងដោយផ្អែកជាសំខាន់លើអង្គហេតុតែមួយ"[17]។ ហេតុដូច្នេះ ការផ្អាកនីតិវិធី អាចត្រូវ បានអនុញ្ញាត ក្នុងករណីដែលមានកំហុសនីតិវិធី[18] និង "ក្នុងករណីកំហុសនោះរំលោភសិទ្ធិរបស់

---

[15] *សូមមើល* រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩ មាត្រា៣១។ មាត្រានេះតម្រូវឲ្យ តុលាការកម្ពុជា "ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

[16] មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា៖ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទ ព្រហ្មទណ្ឌណាមួយប្រឆាំងមកលើជនណាមួយ ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាង ពេញលេញ ក្នុងការមានពេលវេលា និងសម្ភារៈ គ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងប្រាស្រ័យទាក់ទងជាមួយមេធាវី ដែលជ្រើសរើសដោយជននោះ។"

[17] *រឿងក្តី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំសួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D264/1, ERN: 00422607-00422618, កថាខណ្ឌ៣០ ("ដីកាសម្រេចស្តីពីសំណើសុំមោឃភាពរបស់ អៀង ធីរិទ្ធ")។

[18] វិធាន៤៨ នៃវិធានផ្ទៃក្នុង។

ភាគីធ្វើពាក្យបណ្តឹង"[19]។

## III. ទឡ្ហីករណ៍

### ក. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក មានលក្ខណៈខុសពីកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ តុលាការព្រហ្មទណ្ឌសាមញ្ញនៅក្នុងប្រទេសកម្ពុជា

១១. វិធានផ្ទៃក្នុង ចែងអំពីបែបបទទាំងឡាយស្តីពីនីតិវិធីជំនុំជម្រះ ដែលមានលក្ខណៈខុសពីបែបបទនានាអនុវត្តនៅតាមបណ្តាតុលាការសាមញ្ញរបស់ប្រទេសកម្ពុជា។ តុលាការព្រហ្មទណ្ឌសាមញ្ញនៅក្នុងប្រទេសកម្ពុជាអនុវត្តនីតិវិធីសួរដេញដោលដឹកនាំដោយចៅក្រម។ ស្ថាប័នអយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌលើជនត្រូវចោទ ហើយសុំឱ្យតុលាការអនុវត្តច្បាប់[20]។ ស្ថាប័នអយ្យការមិនមានបន្ទុកនៅក្នុងការបង្ហាញភស្តុតាងនោះទេ។ នៅពេលជំនុំជម្រះគឺចៅក្រមនោះទេ ដែលជាអ្នកមានបន្ទុក

---

[19] ដីកាសម្រេចស្តីពីសំណើសុំមោឃភាពរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ៣០, យោងតាមការមោឃភាពលើកិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការ។ ទាក់ទិននឹងការមោឃភាព អង្គបុរេជំនុំជម្រះបានរៀបរាប់ថា "ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនត្រូវ-ចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជាកំហុសនីតិវិធី ហើយនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជន- ត្រូវចោទ។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកថាមោឃៈ" *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៦), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, ឯកសារ D55/I/8, ERN: 00219322-00219333 ("សាលដីកាលើពាក្យសុំមោឃភាពរបស់ នួន ជា"), កថាខណ្ឌ៤០។ អង្គបុរេក៏បានលើកឡើងដែលថា សំណើសុំផ្អាកដំណើរការនីតិវិធីអាចស្ថិតនៅ "ក្នុងដែនកំណត់ទូទៅនៃពាក្យបណ្តឹងណាមួយ ដែលស្ថិតនៅក្រោមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្នុងនោះចែងពាក់ព័ន្ធថា 'ការជំនុំជម្រះក្តីត្រូវតែយុត្តិធម៌' ហើយត្រូវប្រព្រឹត្តទៅ 'ដោយគោរពយ៉ាងពេញលេញទៅលើសិទ្ធិរបស់ជនជាប់ចោទ ..." *រឿងក្តី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6, ERN: 00543781-00543799, កថាខណ្ឌ១៣។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៧។

នៅក្នុងការស្វែងរកការពិត[21] ដោយនឹងត្រូវធ្វើឡើងតាមរយៈការប្រើប្រាស់ភស្តុតាងនៅក្នុងសំណុំរឿង ឬភស្តុតាង ដែលបានដាក់ដេញដោលនៅពេលសវនាការ[22]។ តាមទម្លាប់អនុវត្ត ចៅក្រម អានសំណុំរឿងទាំងមូលមុនពេលជំនុំជម្រះ ហើយក្រោយមកនឹងធ្វើការសម្រេចលើរឿងក្តី ក្រោយពីខ្លួនមានជំនឿស្មោះត្រង់ពិតប្រាកដ[23]។ ចៅក្រមនឹងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនថានឹងត្រូវដំណើរការរឿងក្តីរបស់ខ្លួនតាមរបៀបណា ដោយរួមទាំងការពិចារណាថាតើគួរកោះហៅសាក្សីណាខ្លះមកផ្តល់សក្ខីកម្ម*ផ្ទាល់* តាមលំដាប់លំដោយនៃសាក្សីដែលខ្លួនត្រូវកោះហៅ[24]។ល។

១២. នៅពេលបង្ហាញថា ក.ស.ព មានបន្ទុកក្នុងការបង្ហាញភស្តុតាង[25] អ.វ.ត.ក បានណែនាំនីតិវិធីនានាដែលមានមូលដ្ឋានចេញមកពីប្រព័ន្ធដេញដោលដោយគូភាគី ដូច្នេះ ផ្តល់អានុភាពឱ្យភាគីជាអ្នកដឹកនាំកិច្ចដំណើរការនីតិវិធី ពោលគឺ ភាគីជាអ្នកទទួលខុសត្រូវលើការបង្ហាញលើរឿងក្តីរបស់ខ្លួន ទោះបីជាមានសំណុំរឿងរួចហើយក៏ដោយ។ សំណុំរឿងនេះទំនងជាមានអង្គហេតុជាច្រើនគគោក សម្រាប់ជាមូលដ្ឋាននៅក្នុងការជំនុំជម្រះរួចទៅហើយ។ វិធានផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវធ្វើឡើង"ចំពោះមុខ"[26] ជាចំណុចដែលបានទទួលស្គាល់ដោយ ក.ស.ព យ៉ាងពិត

---

[21] *សូមអាន ឧទាហរណ៍* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២៥ ដែលចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ "ប្រធានសវនាការសួរគ្រប់សំនួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឱ្យឃើញការពិត"។

[22] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ "តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬ ដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ"។

[23] *ដូចមាត្រាខាងលើ៖* "តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន"។

[24] មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា៖ "ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី"។

[25] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[26] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

ប្រាកដ[27]។ ការបញ្ជាក់បន្ថែមថា កិច្ចដំណើរការនីតិវិធីនេះត្រូវបានដឹកនាំដោយភាគី អាចមើលឃើញតាមរយៈការផ្តល់សិទ្ធិធ្វើសេចក្តីសន្និដ្ឋានបើក ដល់ ក.ស.ព និងក្រុមមេធាវីការពារក្តី[28] និងសិទ្ធិដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុំជំម្រះសាលាដំបូង[29]។ វិធានផ្ទៃក្នុងមានអានុភាពលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[30]។ ហេតុដូច្នេះ វាមានលំនាំថា *ជាបឋម* ក.ស.ព *ត្រូវ* បង្ហាញរឿងក្តី*របស់ខ្លួន*ដើម្បីបង្ហាញភស្តុតាងពីពិរុទ្ធភាពទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

១៣. ដោយសារកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយ ក.ស.ព មានបន្ទុកនៅក្នុងការបង្ហាញភស្តុតាង ភាគីទាំងឡាយជាភាគីសមបំផុតក្នុងការដឹកនាំការសួរដេញដោលសំខាន់ៗលើសាក្សី។ វាពិតតែត្រឹមត្រូវបំផុត ដែលអង្គជំនុំជម្រះគួរតែសួរដេញដោលនូវសំណួរទាំងឡាយណា ក្នុងគោលបំណងបំភ្លឺបញ្ជាក់តែប៉ុណ្ណោះ ដោយមិនមានបន្ទុកនៅក្នុងការបង្ហាញភស្តុតាងឡើយ ដោយហេតុវាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។

១៤. វិធានផ្ទៃក្នុងពុំមានចំណុចខ្វែងគ្នា ឬ ភាពប្រទាំងប្រទើសចាក់ស្រេះរវាងបន្ទុករបស់ ក.ស.ព នៅក្នុងការបង្ហាញភស្តុតាង និងការចែងយោងលើតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការស្វែងរកការពិតនោះទេ។ ការសរសេរយោងបែបនេះ ត្រូវយកមកពិចារណាដោយគិតថាជាការបង្វែរបន្ទុកភស្តុតាងទៅឱ្យ ក.ស.ព ពោលគឺ វាខុសពីតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការបញ្ជាក់ការពិត ព្រមទាំងត្រូវយកមកពិចារណាដោយគិតអំពីបែបបទនីតិវិធីជំនុំជម្រះដេញដោលដោយភាគី

[27] "វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងចែងអំពីកិច្ចដំណើរការនីតិវិធីដោយគោរពគោលការណ៍ចំពោះមុខនៅ អ.វ.ត.ក ដែលជាគម្រូនៃនីតិវិធីជំនុំជម្រះតាមច្បាប់ព្រហ្មទណ្ឌនៃប្រព័ន្ធច្បាប់ខំមិនឡូ"។ អនុស្សរណៈអន្តរការិយាល័យពី ក.ស.ព ដាក់ជូនទៅ Susan Lamb មន្ត្រីសម្របសម្រួលតុលាការ "សំណើសុំវិសោធនកម្មលើវិធានចំនួន ២ ដើម្បីឱ្យនីតិវិធីជំនុំជម្រះកាន់តែមានប្រសិទ្ធភាពដោយវាពាក់ព័ន្ធនឹង (១) ការបង្ហាញភស្តុតាងនៅពេលជំនុំជម្រះ និង (២) ការដេញដោលសំនួរលើជនជាប់ចោទ និងសាក្សី" ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ទំព័រទី៦។

[28] វិធាន ៨៩ *ស្ទួន* (២) នៃវិធានផ្ទៃក្នុងចែងថា "នៅមុនពេលសួរចម្លើយជនជាប់ចោទ សហព្រះរាជអាជ្ញា អាចធ្វើសេចក្តី សន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬ មេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន"។

[29] វិធាន ៨០ នៃវិធានផ្ទៃក្នុង។

[30] សាលដីកាលើសំណើសុំមោឃភាពរបស់ នួន ជា កថាខណ្ឌ១៤។

ដែលវិធានផ្ទៃក្នុងបានបញ្ញត្តិយ៉ាងត្រង់ៗ[31]។

---

[31] វិធាន ៨៥ នៃវិធានផ្ទៃក្នុងចែងថា៖ "ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និង ជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ចៅក្រមផ្សេងទៀត។ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត" (គូសបញ្ជាក់ បន្ថែម)។ កាតព្វកិច្ចរបស់ប្រធាន អនុលោមតាមវិធាន ៨៥(១) នៃវិធានផ្ទៃក្នុង មិនមានលក្ខណៈផ្ទុយពីកិច្ចដំណើរការនីតិវិធីដឹកនាំ ដោយគូភាគីក្តី វិធាន ៨៧(១) ឬ នីតិវិធីជំនុំជម្រះដែលបានស្នើសុំឡើយ។ វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង ចែងធានាថា ការដេញដោលសំនួរដែលដឹកនាំដោយភាគី នឹងមិននាំឱ្យមានការសួរដេញដោលសំនួរចាកអង្គហេតុ ដោយសារការសួរដេញដោលដោយផ្ទាល់ ឬ ការសួរដេញដោលទៅគូក្តីនោះទេ ឧទាហរណ៍ ក. ការសួរសំនួរដែលមិនពាក់ព័ន្ធនឹងអង្គហេតុដែលមានវិវាទ ដោយសារការកម្រិតការសួរដេញដោល ឧទាហរណ៍ លើតែព័ត៌មាន ដែលត្រូវបានធ្លេចឱ្យចេញ គឺមិនបានការចំពោះអង្គហេតុដែលមានវិវាទ ឬ មិនពាក់ព័ន្ធ។ ឬ ខ. ដោយគ្រាន់តែសួរសំនួរទាំងឡាយណា ដែលមានចម្លើយផ្តល់ឱ្យរួចទៅហើយ (ពោលគឺ សំនួរដដែលៗ)។ ប្រធានក៏អាចពិចារណាផងដែរថា ខ្លួនអាចប្រើប្រាស់វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ដើម្បីដាក់កម្រិត ឬ ហាមឃាត់ភាគីដែលសួរទៅគូក្តីមិនឱ្យសួរសំនួរទាំងឡាយណា ដែលមានលក្ខណៈពាក់ព័ន្ធនឹងបុគ្គលផ្ទាល់ និងក្នុងករណីដែលហេតុផលនៃការសួរសំនួរគឺគ្រាន់ដើម្បីធ្វើឱ្យសាក្សីអាម៉ាស។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងចែងថា៖ "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាម ខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាង ដែលបានស្នើសុំនោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ" (ការគូសបញ្ជាក់បន្ថែម)។ វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង មិនមានលក្ខណៈផ្ទុយពីកិច្ចដំណើរការនីតិវិធីដឹកនាំដោយគូភាគីក្តី វិធាន ៨៧(១) ឬ នីតិវិធីជំនុំជម្រះដែលបានស្នើសុំឡើយ។ វិធាននេះ ធានាឱ្យអង្គជំនុំជម្រះអាចគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីទាំងមូល និងទុកសិទ្ធិឱ្យចៅក្រមក្នុងការកោះហៅសាក្សី ឬ ស្តាប់ភស្តុតាង តាម*គំនិតផ្តួចផ្តើមរបស់ខ្លួន*។ បទប្បញ្ញត្តិស្រដៀងគ្នា មានចែងនៅក្នុងវិធានស្តីពីនីតិវិធី និងភស្តុតាង នៅ ICTY។ *សូមអាន* វិធានស្តីពីនីតិវិធី និងភស្តុតាងនៅ ICTY ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ដោយវិធាន ៩៨ ចែងថា៖ "អង្គជំនុំជម្រះអាចបង្គាប់ឱ្យភាគីណាមួយផ្តល់នូវភស្តុតាងបន្ថែម។ អង្គជំនុំជម្រះ តាម*គំនិតផ្តួចផ្តើមរបស់ខ្លួន* អាចកោះហៅសាក្សី និងបង្គាប់ឱ្យសាក្សីចូលរួម"។ *សូមអានផងដែរនូវ* វិធានស្តីពីនីតិវិធី និងភស្តុតាងនៅ ICTY ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ("វិធានស្តីពីនីតិវិធី និងភស្តុតាងនៅ ICTY") ដោយវិធាន ៩០ (ច)(i) បានបង្ហាញបន្ថែមអំពីនត្តិភាពនៃភាពមិនស៊ីសង្វាក់គ្នារវាងរដ្ឋអាជ្ញា ដែលមានបន្ទុកនៅក្នុងការបង្ហាញភស្តុតាង និងតួនាទីរបស់អង្គជំនុំជម្រះនៅក្នុងការបញ្ជាក់នូវការពិត។

១៥. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាមានភាពប្រទាំងប្រទើសនោះ ខ្លួនត្រូវយកមកពិចារណាដោយគិតពី ក) សិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស[32] និង ខ) គោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[33]។ ក្នុងករណីមានវិមតិសង្ស័យណាមួយចំពោះនីតិវិធីដែលត្រូវអនុវត្ត អង្គជំនុំជម្រះសាលាដំបូងត្រូវដោះស្រាយក្នុងលក្ខណៈមួយផ្តល់ជាប្រយោជន៍ដល់លោក អៀង សារី។ នីតិវិធីជំនុំជម្រះដែលបានស្នើឡើង នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការដឹកនាំសំណុំរឿងលេខ ០០២ ក្នុងលក្ខណៈមួយឆាប់រហ័សបំផុត[34] ដោយវាបានដោះស្រាយលើភាពមិនស៊ីសង្វាក់គ្នានេះ និងអនុញ្ញាតឱ្យអង្គជំនុំជម្រះរក្សាការគ្រប់គ្រងទាំងមូលលើកិច្ចដំណើរការនីតិវិធី។

១៦. ភាពប្រទាំងប្រទើសរវាង ក.ស.ព នៅក្នុងការបង្ហាញការចោទប្រកាន់ដើម្បីបំពេញតាមលក្ខខណ្ឌនៃបន្ទុកក្នុងការបង្ហាញភស្តុតាង និងអង្គជំនុំជម្រះនៅក្នុងការដឹកនាំការសួរដេញដោល មិនឃើញកើតមាននៅក្នុងសំណុំរឿងលេខ ០០១ នោះទេ ដោយហេតុថា វាមិនមានការជំនុំជម្រះដែលត្រូវបានតវ៉ាពោលគឺ ដោយហេតុថា វាជាសវនាការយ៉ាងវែងលើការផ្លាស់ប្តូរចម្លើយសារភាព / សវនាការសម្រេចលើទោសទណ្ឌ ក្នុងគោលបំណងបញ្ជាក់ថាតើការសារភាពរបស់ ឌុច បានបំពេញធាតុផ្សំនៃបទល្មើសដែលដាក់បន្ទុកលើខ្លួន ហើយដើម្បីកំណត់ទោសសមស្របតែប៉ុណ្ណោះ។ ក.ស.ព បានរួចផុតពីបន្ទុកនៅក្នុងការបង្ហាញយ៉ាងមានប្រសិទ្ធិភាព ដោយសារ ឌុច បានសារភាពស្ទើរតែគ្រប់អង្គហេតុទាំងអស់ ដែលបង្ហាញអំពីពិរុទ្ធភាពរបស់ជននេះ ហើយបានសារភាពលើគ្រប់ការចោទប្រកាន់របស់ ក.ស.ព។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *ឌុច* អាចដឹកនាំការសួរដេញដោលលើសាក្សីទាំងឡាយយ៉ាងងាយ ដោយមិនមានការជ្រៀតជ្រែកចូលកាតព្វកិច្ចរបស់ ក.ស.ព ក្នុងការបង្ហាញភស្តុតាងនោះទេ។

---

[32] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី។

[33] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ១៩៩៩ មាត្រា ៣៨ ចែងថា "វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។

[34] *សូមអាន ដូចខាងក្រោម* កថាខណ្ឌ២៦ ដល់ កថាខណ្ឌ២៩។

## ខ. នីតិវិធីនៅក្នុងសំណុំរឿងលេខ ០០១ មិនអាចយកមកប្រើប្រាស់នៅក្នុងសំណុំរឿងលេខ ០០២ បានឡើយ ដោយសារវាជាការបង្វែរបន្ទុករបស់ ក.ស.ព ក្នុងការបង្ហាញភស្តុតាង

១៧. ភាពខុសគ្នាជាសារវន្តរវាងសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ គឺ សំណុំរឿងលេខ ០០២ មានការតវ៉ា។ វិធានផ្ទៃក្នុងចែងច្បាស់ថា ក.ស.ព មានបន្ទុកនៅក្នុងការបង្ហាញពិរុទ្ធភាព[35]។ វិធីតែមួយគត់ដែល ក.ស.ព អាចព្យាយាមនៅក្នុងការបង្ហាញពិរុទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធីដែលមានការតវ៉ា និងចំពោះមុខដូច្នេះ ដោយមិនចាំបាច់បង្វែរបន្ទុកបង្ហាញភស្តុតាងរបស់ខ្លួននោះ គឺតាមវិធីធ្វើការបង្ហាញការចោទប្រកាន់ទាំងមូលជូនអង្គជំនុំជម្រះសាលាដំបូង មុនពេលក្រុមមេធាវីការពារក្តីបង្ហាញរឿងក្តីរបស់ខ្លួន។ ដូចគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីគួរធ្វើការបង្ហាញរឿងក្តីទាំងមូលរបស់ខ្លួនជូនអង្គជំនុំជម្រះសាលាដំបូងផងដែរ មុនពេលក្រុមមេធាវីការពារក្តីធ្វើការបង្ហាញរឿងក្តីរបស់ខ្លួន[36]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការស្តាប់ភស្តុតាងតាមលំដាប់លំដោយ ដែលខ្លួនយល់ឃើញថាចាំបាច់ក៏ដោយ[37] ក៏ជនជាប់ចោទមិនមានបន្ទុកនៅក្នុងការបង្ហាញឡើយ ហើយក៏មិនត្រូវបានគេទាមទារឱ្យផ្តល់ព័ត៌មានទាំងឡាយដែរ[38]។ ដីកាបង្គាប់ ឬ សំណើណាមួយឱ្យលោក អៀង សារី ផ្តល់ព័ត៌មាន មុនពេលមានការចោទប្រកាន់រឿងក្តីទាំងមូលលើខ្លួននោះ គឺជាការបង្វែរបន្ទុករបស់ ក.ស.ព ក្នុងការបង្ហាញពិរុទ្ធភាព ទៅឱ្យលោក អៀង សារី បង្ហាញនូវភាពគ្មានទោសរបស់ខ្លួន ដោយធ្វើឱ្យមានការរំលោភលើសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងជាការរំលោភលើវិធានផ្ទៃក្នុង[39]។

---

[35] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[36] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង។

[37] វិធាន ៩០ និងវិធាន ៩១ នៃវិធានផ្ទៃក្នុង។

[38] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី(ឆ)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ឆ)។

[39] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ១៩៩៩ មាត្រា ៣៨។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី។ វិធាន ២១(១)(ឃ) វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ១១(១)។

១៨. សទិសភាពអាចទាញចេញពីតុលាការ ICC និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") ដោយសារតុលាការទាំងពីរបានធ្វើការជំនុំជម្រះលើរឿងក្តីធំ និងស្មុគស្មាញស្រដៀងនឹង អ.វ.ត.ក។ នៅតុលាការ ICC[40] និងតុលាការ ICTY[41] បន្ទុកនៃការបង្ហាញភស្តុតាង ក៏ធ្លាក់ទៅលើស្ថាប័នអយ្យការដែរ។ នៅតុលាការ ICC ប្រសិនបើចៅក្រមប្រធានមិនបានធ្វើការបង្គាប់ទេនោះ អយ្យការ និងក្រុមមេធាវីការពារក្តី ធ្វើការឯកភាពគ្នាលើលំដាប់លំដោយ និងរបៀបដែលភស្តុតាងត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង[42]។ តាមទម្លាប់អនុវត្តនៅតុលាការ ICC អយ្យការធ្វើការបង្ហាញការចោទប្រកាន់ជាមុន បន្ទាប់មកក្រុមមេធាវីការពារក្តី[43]។ ការអនុវត្តបែបនេះរារាំងមិនឱ្យធ្វើការបង្វែរបន្ទុកនៃការបង្ហាញពីស្ថាប័នអយ្យការ[44]។ នៅតុលាការ ICTY ដោយហេតុថាស្ថាប័នអយ្យការមានបន្ទុកនៅក្នុងការបង្ហាញភស្តុតាង អយ្យការធ្វើការចោទប្រកាន់ជាមុន បន្ទាប់មក

---

[40] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៦(២)៖ "រដ្ឋអាជ្ញាមានបន្ទុកនៅក្នុងការបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទ"។

[41] "ក្នុងករណីស្ថាប័នអយ្យការមានកាតព្វកិច្ចត្រូវបង្ហាញការចោទប្រកាន់លើជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ ជនជាប់ចោទទាមទារឱ្យបង្ហាញបញ្ហានានា ដែលខ្លួនអាចផ្អែកលើតុល្យភាពនៃសមាមាត្រ"។ *រដ្ឋអាជ្ញា ទល់នឹង Delalić* និងជនដទៃទៀត IT-96-21-T សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦០៣។

[42] វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICC ចុះថ្ងៃទី៣ ដល់ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ ("វិធានស្តីពីនីតិវិធី និង ភស្តុតាងនៃតុលាការ ICC") វិធាន ១០៤(១)។

[43] *សូមអាន ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* ICC-PIDS-CIS-DRC2-01-001/09 ព័ត៌មានស្តីពីប្រវត្តិ សំនួរ និងចម្លើយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩៖ "នៅពេលសវនាការ ការិយាល័យរដ្ឋអាជ្ញា នឹងធ្វើការបង្ហាញភស្តុតាងទាំងអស់ នៅពេលណាក៏ដោយ ដោយដាក់ជូននូវឯកសារជាច្រើន ដែលបានចងក្រងនៅក្នុងសំណុំរឿង រួមទាំងសម្រង់ចេញពីការថតសោតទស្សន៍ ឱ្យចៅក្រមពិចារណា។ ការិយាល័យរដ្ឋអាជ្ញា អាចកោះហៅសាក្សីចំនួន ២៦ នាក់ ដោយរួមទាំងសាក្សីជំនាញ។ បន្ទាប់មក មេធាវីការពារក្តីអាចមានឱកាសធ្វើការសួរទៅសាក្សីដាក់បន្ទុក...ក្រោយពីសន្និដ្ឋានការចោទប្រកាន់ប្រហែលជាក្នុងរយៈពេលប៉ុន្មានខែប៉ុណ្ណោះ ក្រុមមេធាវីការពារក្តីនឹងធ្វើការបង្ហាញភស្តុតាងដោះបន្ទុកដែលខ្លួនមាន ហើយនឹងធ្វើការកោះហៅសាក្សីមួយចំនួន ដើម្បីជាមូលដ្ឋានលើភស្តុតាងដោះបន្ទុករបស់ខ្លួន។ សាក្សីទាំងនេះនឹងត្រូវបានដេញដោលដោយមេធាវីការពារក្តី និងបន្ទាប់មកសួរដេញដោលពីរដ្ឋអាជ្ញា"។

[44] មាត្រា ៦៧(១)(i) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថា ជនជាប់ចោទ៖ "មិនត្រូវបានគេដាក់បន្ទុកលើខ្លួនឱ្យបង្ហាញភស្តុតាង ឬ បន្ទុកនៅក្នុងការសន្និដ្ឋានតបនោះទេ។

ក្រុមមេធាវីការពារក្តី[45]។ សទិសភាពប្រសើរបំផុត អាចទាញពីនីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("តុលាការ STL")។ តុលាការ STL យកច្បាប់ជាតិមកអនុវត្ត[46] និងមានវិធាន *ពិសេស*ស្តីពីនីតិវិធី[47]។ ប្រព័ន្ធតតិយុត្តរបស់ប្រទេសលីបង់ ផ្អែកតាមប្រព័ន្ធតតិយុត្តរបស់ប្រទេសបារាំង[48]។ នៅតុលាការ STL បន្ទុកនៃការបង្ហាញភស្តុតាង ក៏ធ្លាក់ទៅលើរដ្ឋអាជ្ញាដែរ[49]។ នៅទីនោះ "ដើម្បីជាប្រយោជន៍យុត្តិធម៌" អយ្យការបង្ហាញ ការចោទប្រកាន់ជាមុន បន្ទាប់មកជនរងគ្រោះដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយនៅចុងក្រោយ គឺក្រុមមេធាវីការពារក្តី[50]។ ដោយហេតុថា

---

[45] វិធានស្តីពីនីតិវិធី និងភស្តុតាង ICTY វិធាន ៨៥(ក) ចែងថា៖ "ភាគីនីមួយៗមានសិទ្ធិកោះហៅសាក្សី និងបង្ហាញភស្តុតាង។ លើកលែងតែមានការបង្គាប់ផ្សេងពីអង្គជំនុំជម្រះសាលាដំបូងដើម្បីជាប្រយោជន៍យុត្តិធម៌ ភស្តុតាងបង្ហាញនៅពេលជំនុំជម្រះត្រូវធ្វើឡើងតាមលំដោយលំដោយដូចតទៅ៖ (១) ភស្តុតាងរបស់រដ្ឋអាជ្ញា (២) ភស្តុតាងរបស់ក្រុមមេធាវីការពារក្តី (៣) ភស្តុតាងរបស់រដ្ឋអាជ្ញា នៅពេលសន្និដ្ឋានតប (៤) ភស្តុតាងរបស់ក្រុមមេធាវីការពារក្តីនៅក្នុងពេលឆ្លើយតប (៥) ភស្តុតាងតាមការ អញ្ជើញរបស់អង្គជំនុំជម្រះសាលាដំបូង តាមវិធាន ៩៨ (៦) ព័ត៌មានពាក់ព័ន្ធទាំងឡាយណា ដែលអាចជួយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការសម្រេចទោសសមស្រប ក្នុងករណីជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព លើបទចោទមួយ ឬច្រើន នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។

[46] លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ S/RES/1757 (២០០៧) ("លក្ខន្តិកៈ STL") ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មាត្រា ២។

[47] វិធានស្តីពីនីតិវិធី និងភស្តុតាង តុលាការពិសេសសម្រាប់ប្រទេសលីបង់ STL/BD/2009/01/វ. ៣ ("វិធានស្តីពីនីតិវិធី និងភស្តុតាង") ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

[48] Firas El Samad ការស្រាវជ្រាវ និងប្រព័ន្ធតតិយុត្តប្រទេសលីបង់ កម្មវិធី HAUSER GLOBAL LAW SCHOOL PROGRAM NYU LAW ចុះវិច្ឆិកា/ធ្នូ ឆ្នាំ២០០៨ *អាចមើលបានតាមរយៈ:* http://www.nyulawglobal.org/Globalex/Lebanon.htm#_2._Legal_system។

[49] សូមអានលក្ខន្តិកៈ STL មាត្រា ១៦(៣)(ខ)។

[50] វិធានស្តីពីនីតិវិធី និងភស្តុតាងប្រទេសលីបង់ វិធាន ១៤៦(ខ) ចែងថា៖ "លើកលែងតែមានការបង្គាប់ផ្សេងពីនេះ ដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីជាប្រយោជន៍យុត្តិធម៌ ភស្តុតាងត្រូវបង្ហាញនៅពេលជំនុំជម្រះត្រូវធ្វើឡើងតាមលំដាប់លំដោយ ដូចតទៅ៖ (១) ភស្តុតាងរបស់រដ្ឋអាជ្ញា (២) ភស្តុតាងតាមការអញ្ជើញរបស់អង្គជំនុំជម្រះសាលាដំបូង តាមសំណើរបស់ជនរងគ្រោះ ដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី (៣) ភស្តុតាងរបស់ក្រុមមេធាវីការពារក្តី (៤) ភស្តុតាងរបស់រដ្ឋអាជ្ញា នៅពេលសន្និដ្ឋានតប (៥) ភស្តុតាងនៅពេលសន្និដ្ឋានតប តាមការអញ្ជើញរបស់ជនរងគ្រោះ ដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី (៦) ភស្តុតាងរបស់ក្រុមមេធាវីការពារក្តីនៅក្នុងពេលឆ្លើយតប"។

បន្ទុកនៃការបង្ហាញនៅ អ.វ.ត.ក គឺធ្លាក់លើ ក.ស.ព ដូចនៅតុលាការ ICC តុលាការ ICTY តុលាការ ICTR និងតុលាការ STL ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគួរមើលបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងនៅតាមបណ្ដាតុលាការទាំងនេះ នៅក្នុងការកំណត់ថា ក.ស.ព និងដើមបណ្ដឹងរដ្ឋប្បវេណីគួរធ្វើការបង្ហាញការចោទប្រកាន់របស់ខ្លួនជាមុន ដែលបន្ទាប់មកក្រុមការពារក្ដីនឹងធ្វើការឆ្លើយតប ឬយ៉ាងណា។

១៩. ដោយហេតុថា បន្ទុកនៃការបង្ហាញភស្តុតាងគឺធ្លាក់លើ ក.ស.ព[51] អង្គជំនុំជម្រះសាលាដំបូងមិនអាចដឹងរហូតដល់ពេល ក.ស.ព បង្ហាញការចោទប្រកាន់នៅក្នុងតុលាការ អំពីរបៀប ក.ស.ព មានបំណងបំពេញបន្ទុកនៃការបង្ហាញភស្តុតាងនេះទេ លើកលែងតែបញ្ជីឈ្មោះសាក្សី និងឯកសារទាំងឡាយដែល ក.ស.ព បានជ្រើសរើសរួចហើយតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងមិនគួរសួរសំនួរទៅកាន់សាក្សី អំពីអ្វីដែលជាការសន្មតរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចោទប្រកាន់របស់ ក.ស.ព លើលោក អៀង សារី ឡើយ។ ការសួរសំនួរដូច្នេះ នឹងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងដើរជំនួសតួនាទីរបស់ ក.ស.ព ហើយនឹងជាការរំលោភលើការបែងចែកតួនាទីរវាង ក.ស.ព ដែលជាស្ថាប័នធ្វើការចោទប្រកាន់ និងអង្គជំនុំជម្រះសាលាដំបូង ដែលជាស្ថាប័នធ្វើការវិនិច្ឆ័យ[52]។

២០. វិសោធនកម្មនីតិវិធី ដែលស្នើសុំ នឹងរារាំងនូវការបង្វែរបន្ទុកនៃការបង្ហាញភស្តុតាង ខណៈដែលនីតិវិធីនេះបានចែងថា ក.ស.ព និងដើមបណ្ដឹងរដ្ឋប្បវេណីនឹងបង្ហាញការចោទប្រកាន់លើរឿងក្ដីរបស់ខ្លួនរៀងៗខ្លួន មុនពេលជនជាប់ចោទបង្ហាញរឿងក្ដីរបស់ខ្លួន។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងជាអ្នកផ្ដួចផ្ដើមការសួរដេញដោលដោយគ្រាន់តែបង្គ្រប់លើបញ្ហានានាក៏ដោយ ក៏ភាគីនីមួយៗជាអ្នកសួរសំនួរសំខាន់ៗលើសាក្សីជាមុនដែរ។

## គ. អង្គជំនុំជម្រះសាលាដំបូងមិនអាចយកដីកាបង្គាប់មកអនុវត្តលើលោក អៀង សារី បានឡើយ

[51] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[52] *សូមអាន* វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

ពីព្រោះវារំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់

២១. ដីកាបង្គាប់ ដាក់កាតព្វកិច្ចឱ្យលោក អៀង សារី ផ្តល់នូវបញ្ជីឈ្មោះសាក្សីបន្ថែមណាមួយដែលគាត់អាចមានបំណងស្នើសុំកោះហៅទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែល ក.ស.ព ផ្តល់បញ្ជីឈ្មោះសាក្សីរបស់ខ្លួនទៅអង្គជំនុំជម្រះសាលាដំបូង[53]។ សម្ភារៈភស្តុតាងស្របតាមវិធាន ៨០ ត្រូវបានស្នើឡើងមុន ក.ស.ព និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ដាក់សំណុំរឿងរបស់ពួកគេក្នុងអំឡុងសវនាការ។ ពុំមានវិធានណាដែលអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យលោក អៀង សារី ផ្តល់នូវសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ បន្ទាប់ពីរឿងក្តីទាំងមូលប្រឆាំងនឹងរូបគាត់ត្រូវបានដាក់បង្ហាញដោយ ក.ស.ព និងភាគីដើមបណ្តឹងរដ្ឋប្បវេណីឡើយ ប្រសិនបើសម្ភារៈភស្តុតាងនោះ អាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ[54]។ តាមរយៈការដាក់កាតព្វកិច្ចឱ្យលោក អៀង សារី បង្ហាញសម្ភារៈភស្តុតាងដែលនឹងផ្តល់នូវព័ត៌មានសម្រាប់ការការពារខ្លួនគាត់ វិធាន ៨០ និងដីកាបង្គាប់ ផ្លាស់ប្តូរបន្ទុកស្វែងរកភស្តុតាងទៅឱ្យលោក អៀង សារី ក្នុងការបង្ហាញភស្តុតាងពីភាពគ្មានទោសរបស់គាត់ ដូចដែលវិធាន ៨០ និងដីកាបង្គាប់នោះ តម្រូវថា គាត់ត្រូវផ្តល់ព័ត៌មានទៅឱ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងឡាយ មុនការដាក់រឿងក្តីណាមួយប្រឆាំងនឹងរូបគាត់ ដែលជា

---

[53] ដីកាបង្គាប់ កថាខណ្ឌ ២។ ដីកាបង្គាប់ក៏បានតម្រូវឱ្យលោក អៀង សារី ផ្តល់សេចក្តីសង្ខេបនៃអង្គហេតុ ដែលសាក្សីនីមួយៗត្រូវធ្វើសក្ខីកម្ម និងចំណុចនៃការចោទប្រកាន់ដែលសាក្សីនីមួយៗត្រូវធ្វើសក្ខីកម្ម ដោយមិនឱ្យលើសពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១។ ដីកាបង្គាប់បានតម្រូវឱ្យលោក អៀង សារី ផ្តល់បញ្ជីឯកសារ និងវត្ថុតាងដែលខ្លួនមានបំណងដាក់ ជូន ដោយមានការពន្យល់សង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា និងបញ្ជីភស្តុតាងថ្មី ដោយមិនឱ្យលើសពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១។

[54] វិធាន ៨៧(៤)៖ "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែល មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការ ស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារ ដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។ (សេចក្តីបញ្ជាក់បន្ថែម)

ការរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌[55]។

២២. ប្រសិនបើលោក អៀង សារី ត្រូវបានបង្ខំឱ្យបង្ហាញសម្ភារៈភស្តុតាងដែលនឹងផ្តល់ព័ត៌មានសម្រាប់ការការពារខ្លួនគាត់មុនរឿងក្តីទាំងមូលប្រឆាំងនឹងរូបគាត់ ត្រូវបានដាក់បង្ហាញក្នុងអំឡុងសវនាការដោយ ក.ស.ព និងភាគីដើមបណ្តឹងរដ្ឋប្បវេណី បុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯងនឹងត្រូវបានរំលោភ ជាការរំលោភលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ[56]។ សេចក្តីណែនាំអាចយកមកពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ក្នុងរឿងក្តី Funke ទល់នឹង ប្រទេសបារាំង[57] និងរឿងក្តី JB ទល់នឹង ប្រទេសស្វីស[58] ដែលសម្រេចថា បុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯងពង្រីកវិសាលភាពទៅដល់ការបង្ខំឱ្យបង្ហាញភស្តុតាង។

២៣. លោក អៀង សារី អាចអនុវត្តបុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯងរបស់គាត់ ដោយមិនផ្តល់នូវសម្ភារៈភស្តុតាងស្របតាមវិធាន ៨០។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើលោក អៀង សារី មិនអនុវត្តតាម ដីកាបង្គាប់ គាត់នឹងមិនអាចផ្តល់នូវសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ នៅដំណាក់កាលលើកក្រោយទៀតក្នុងដំណើរការជំនុំជម្រះទោសឡើយ លើកលែងតែគាត់អាចបង្ហាញថា គាត់មិនអាចរកសម្ភារៈភស្តុតាងនោះបាននៅមុនពេលការចាប់ផ្តើមការជំនុំជម្រះ។ ដូច្នេះ វិធាន ៨០ នឹងមិនអនុញ្ញាតឱ្យលោក អៀង សារី ទទួលបាននូវសម្ភារៈ/មធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួនគាត់ ដែលជាការរំលោភលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ[59] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[60]។

---

[55] សូមមើល រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដោយត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩ មាត្រា៣៨។ ច្បាប់ស្តីពីការ បង្កើតអង្គជំនុំជម្រះវិសាមញ្ញ មាត្រា៣៥ថ្មី។ វិធាន២១(១)(ឃ) ៨៧(១)។ កតិកាសញ្ញាអន្តជាតិ ICCPR មាត្រា១៤(២)។ UDHR មាត្រា១១(១)។

[56] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មាត្រា៣៥ថ្មី(ឆ)។

[57] រឿងក្តី *Funke ទល់នឹង ប្រទេសបារាំង* ពាក្យសុំលេខ 10828/84 សាលក្រម ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៣ កថាខណ្ឌ៤៤។

[58] រឿងក្តី *J.B ទល់នឹង ប្រទេសស្វីស* ពាក្យសុំលេខ 31827/94 សាលក្រម ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៦៤។

[59] មាត្រា ៣៥ថ្មី(ខ) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

[60] កតិកាសញ្ញាអន្តរជាតិ ICCPR មាត្រា ១៤(៣)(ខ)។

២៤. សំណុំរឿង ០០១ ផ្តល់នូវសេចក្តីណែនាំតិចតួចចំពោះថាតើវិធាន ៨០ គួរត្រូវបានអនុវត្តបែបណានៅក្នុងរឿងក្តីនេះ ប្រសិនបើមាន។ ក្នុងរឿងក្តី ០០១ មេធាវីការពារក្តីបានដាក់បញ្ជីភស្តុតាង និងឈ្មោះសាក្សីស្របតាមវិធាន ៨០ មុនពេលការចាប់ផ្តើមការជំនុំជម្រះ[61]។ ចម្លើយសារភាពរបស់ ឌុច បានដកបន្ទុកស្វែងរកភស្តុតាងរបស់ ក.ស.ព ប្រកបដោយប្រសិទ្ធភាព ដោយអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមវិធាន ៨០ ដោយមិនរំលោភទៅលើបុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯង ឬដោយមិនបានបដិសេធផ្តល់ឲ្យគាត់នូវសម្ភារៈ/មធ្យោបាយគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួនគាត់ឡើយ។ សំណុំរឿង ០០២ ត្រូវបានជំទាស់តវ៉ា ហើយ ក.ស.ព រក្សាបន្ទុកស្វែងរកភស្តុតាងរបស់ខ្លួន ។ វិធាន ៨០ គឺជាវិធានស្តីពីនីតិវិធី ដែលមិនបានការពារនូវសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ ឬអនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិឡើយ[62]។

២៥. វិសោធនកម្មនីតិវិធីដែលបានស្នើសុំ អនុញ្ញាតឲ្យលោក អៀង សារី បង្ហាញសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ បន្ទាប់ពី ក.ស.ព និងភាគីរដ្ឋប្បវេណីបានបង្ហាញរឿងក្តីរបស់ពួកគេរួច។ ការអនុវត្តបែបនេះនឹងរក្សាបន្ទុកស្វែងរកភស្តុតាងរបស់ ក.ស.ព រក្សានូវសិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស រក្សាបុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯងរបស់លោក អៀង សារី និងអនុញ្ញាតឲ្យលោក អៀង សារី ទទួលបាននូវសម្ភារៈ/មធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំ ការពារខ្លួនគាត់។

---

[61] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" 001/18-07-2007-ECCC/TC សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឲ្យភាគីដាក់ឯកសារបន្ថែម ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ E5, ERN: 00250117-00250121។

[62] ឧទាហរណ៍ តុលាការ ICC, ICTY, ICTR និងតុលាការពិសេសសម្រាប់លីបង់ ពុំមានវិធានស្រដៀងទៅនឹងវិធាន៨០ ឡើយ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការICC វិធាន៧៦ គ្រាន់តែចែងអំពីការបង្ហាញឈ្មោះសាក្សីរបស់អយ្យការមុនពេលសវនាការ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ដោយបានធ្វើវិសោធនកម្មនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ វិធាន៦៥ស្ទួនពីរ(ឆ) ស្នើសុំយ៉ាងច្បាស់នូវបញ្ជីឈ្មោះសាក្សី និងភស្តុតាងរបស់មេធាវីការពារក្តី បន្ទាប់ពីមានរឿងក្តីរបស់ អយ្យការ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការICTR ដោយបានធ្វើវិសោធនកម្មនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ វិធាន ៧៣ស្ទួនពីរ ស្នើសុំយ៉ាងច្បាស់នូវបញ្ជីឈ្មោះសាក្សី និងភស្តុតាងរបស់មេធាវីការពារក្តី បន្ទាប់ពីមានរឿងក្តីរបស់អយ្យការ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសលីបង់ STL/BD/2009/01/Rev.3 ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ វិធាន១១២ ស្នើសុំយ៉ាងច្បាស់នូវបញ្ជីឈ្មោះសាក្សី និងភស្តុតាងរបស់មេធាវីការពារក្តី បន្ទាប់ពីមានរឿងក្តីរបស់អយ្យការ។

### ឃ. អង្គជំនុំជម្រះសាលាដំបូងមិនអាចយកដីកាបង្គាប់មកអនុវត្តលើលោក អៀង សារី បានឡើយ ពីព្រោះដីកាបង្គាប់នោះបង្កើតនូវវិសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នារវាងមេធាវីការពារក្តី និង ក.ស.ព

២៦. តាមរយៈការតម្រូវឱ្យលោក អៀង សារី ផ្តល់នូវសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ មុន ក.ស.ព ដាក់បង្ហាញរឿងក្តីរបស់ខ្លួន វិធាន ៨០ និងដីកាបង្គាប់ ក៏បានបង្កើតនូវវិសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នារវាងមេធាវីការពារក្តី និង ក.ស.ព ផងដែរ។ ការផ្តល់សម្ភារៈភស្តុតាងស្របតាមវិធាន ៨០ អនុញ្ញាតឱ្យ ក.ស.ព លើកយកនូវរឿងក្តីរបស់លោក អៀង សារី មុនការដាក់រឿងក្តីរបស់ខ្លួន។ ការធ្វើបែបនេះ ក.ស.ព អាចដាក់រឿងក្តីរបស់ខ្លួនផង និងអាចបដិសេធរឿងក្តីរបស់លោក អៀង សារី ផងក្នុងអំឡុងការបង្ហាញអំពីរឿងក្តីរបស់ខ្លួន មុនពេលមេធាវីការពារក្តីមានឱកាសបង្ហាញនូវរឿងក្តីរបស់ខ្លួននៅសវនាការ។ ប្រការនេះធ្វើឱ្យ ក.ស.ព មានប្រៀបទៅលើលោក អៀង សារី ក្នុងអំឡុងពេលសវនាការ ដែលនាំឱ្យមានវិសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា។ វិសោធនកម្មនីតិវិធីដែលបានស្នើឡើង នឹងរក្សានូវសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា ពីព្រោះលោក អៀង សារី នឹងត្រូវតែផ្តល់សម្ភារៈភស្តុតាងស្របតាមវិធាន ៨០ ដែលជាព័ត៌មានទាក់ទិននឹងការការពារខ្លួនគាត់ បន្ទាប់ពី ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញរឿងក្តីរបស់ពួកគេរួចរាល់ប៉ុណ្ណោះ។

២៧. តាមការយល់ឃើញជាក់ស្តែង ក.ស.ព អាចមានលក្ខណៈងាយស្រួលច្រើនក្នុងការផ្តល់សម្ភារៈភស្តុតាងស្របតាមវិធាន ៨០ នៅមុនការចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២។ ក.ស.ព មានសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ យ៉ាងច្រើននៅក្នុងដៃបន្ទាប់ពីការរៀបចំរបស់ខ្លួនក្នុងសំណុំរឿង ០០១។ មេធាវីការពារក្តីពុំបានចូលរួមក្នុងសំណុំរឿង ០០១ ឡើយ[63]។ ក.ស.ព ត្រូវបានអនុញ្ញាតឱ្យផ្ទេរភស្តុតាងពីសំណុំរឿង ០០១ ទៅក្នុងសំណុំរឿង ០០២[64] ។ មេធាវីការពារក្តីត្រូវបានហាមឃាត់មិន

---

[63] ឧទាហរណ៍ មន្ទីរ ស២១ គឺជាទីកន្លែងឧក្រិដ្ឋកម្មសម្រាប់សំណុំរឿង ០០១ និងសំណុំរឿង ០០២។

[64] សូមមើល រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ D108, ERN: 00236076-00236077។ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារនានាដែលមាននៅក្នុងសំណុំរឿងលេខ០០១ ចូលក្នុងសំណុំរឿង០០២

ឱ្យចូលរួមក្នុងសំណុំរឿង ០០១ ឡើយ[65]។ ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាលទ្ធផលការងាររបស់ ក.ស.ព ដូច្នេះ ក.ស.ព ប្រាកដជាបានប្រមូលសម្ភារៈភស្តុតាងស្របតាមវិធាន ៨០ យ៉ាងច្រើនអស់រយៈពេលជាងបីឆ្នាំមកហើយ[66]។ ក.ស.ព បានបំពេញកិច្ចស៊ើបសួរយ៉ាងច្រើនមុនពេលប្រគល់សំណុំរឿងទៅឱ្យ ក.ស.ច.ស[67]។ ផ្ទុយទៅវិញ មេធាវីការពារក្តីត្រូវបានហាមឃាត់មិនឱ្យបំពេញកិច្ចស៊ើបសួរឡើយ[68] ដូច្នេះតាមពិតគឺ ក.ស.ព ស្ថិតក្នុងតួនាទីដ៏ល្អជាងក្នុងការផ្តល់

---

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D288/1, ERN: 00418084-00418087។ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសដ សេចក្តីសម្រេចលើសំណើរបស់ការិយាល័យសហចៅក្រម ស៊ើបអង្កេតសុំផ្ទេរឯកសារនានាដែលមាននៅក្នុងសំណុំរឿងលេខ០០១ ចូលទៅក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១ ឯកសារ D288/3, ERN: 00424786-00424787។

[65] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសដ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ E90, ERN: 00345178-00345180។

[66] កិច្ចស៊ើបសួរទៅលើសំណុំរឿង ០០២ បានចាប់ផ្តើមដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព។ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 ERN: 00141011-00141166 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។ កិច្ចស៊ើបសួរទៅលើសំណុំរឿង ០០២ បានបញ្ចប់ដោយមានដីកាដំណោះស្រាយ។ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427, ERN: 00604508-00605246 ("ដីកាដំណោះស្រាយ")។

[67] វិធាន៥៣ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "១. ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គ- ជំនុំជម្រះវិសាមញ្ញបានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬ ច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន។ ដីកានេះ ត្រូវមានព័ត៌មានដូចខាងក្រោម៖ ក) សេចក្តីសង្ខេបអំពីអង្គហេតុ ខ) ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ គ) បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ ឃ) ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន និង ង) កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ។ ២. ដីកានេះត្រូវអមដោយសំណុំរឿង និងសម្ភារៈផ្សេងទៀតដែលបានចាត់ទុកជាភស្តុតាង ដែលសហ-ព្រះរាជអាជ្ញាមាន រួមទាំងអ្វីៗទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភស្តុតាងដោះបន្ទុកផងដែរ។

[68] រឿងក្តី នួន ជា ការិយាល័យសហចៅក្រមស៊ើបអង្កេត ការឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីកិច្ចស៊ើបអង្កេត ឯកសារ A110/I ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ទំព័រ២។ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-

សម្ភារៈភស្តុតាងស្របតាមវិធាន ៨០ នៅពេលនេះ។

### ង. នីតិវិធីដែលបានស្នើសុំឱ្យមានការកែប្រែ នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង និងជួយឱ្យដំណើរការនីតិវិធីដំណើរការទៅមុខឱ្យបានឆាប់រហ័ស

២៨. ក.ស.ព បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០២ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ហើយបានពាក់ព័ន្ធក្នុងការបំពេញកិច្ចស៊ើបសួរ ក្នុងវិសាលភាពដែលអនុញ្ញាតដោយវិធាន ដូចគ្នាជាមួយមេធាវីការពារក្តីដែរ[69]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានពិនិត្យលើសំណុំរឿង ដែលមាន ៣៥០.០០០ ទំព័រ ប៉ុណ្ណោះ[70] ចាប់តាំងពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០[71]។ ដូច្នេះ មានភាវនីយហេតុដ៏សមហេតុផលមួយដែលថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនអាចអាន និងពិចារណាឱ្យបានល្អិតល្អន់ទៅលើសំណុំរឿងដ៏ធំទាំងមូលនៅមុនពេលចាប់ផ្តើម ដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២ បានឡើយ[72]។ ដោយមិនបានធ្វើការវិភាគឱ្យបានពេញលេញលើសំណុំ

---

អវតក/កសចស ដីកាសម្រេចធ្វើការព្រមាន ដោយអនុវត្តតាមវិធាន៣៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D367, ERN: 00478513-00478519 កថាខណ្ឌ ៩។

[69] វិធាន៥៥(១០) ផ្តល់សិទ្ធិឱ្យ ក.ស.ព មេធាវីការពារក្តី និងភាគីទាំងអស់ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ។ ក.ស.ព និងមេធាវីការពារក្តីបានស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរជាច្រើនដង។ សូមមើល ឧទាហរណ៍ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា [DC-CAM] ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D242, ERN: 00402284-00402288។ រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើលើកទីពីររបស់ អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ឯកសារ D160, ERN: 00302361-00302370។

[70] ដីកាដំណោះស្រាយ កថាខណ្ឌ ១៧។

[71] វិធាន៦៩(៣) ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំ ជម្រះនៅពេលដែលដីកាដំណោះស្រាយត្រូវចេញ។

[72] សូមមើល គម្រោងយុត្តិធម៌នៅកម្ពុជា (OSJI) ការវិវឌ្ឍន៍ថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០៩ ("OSJI ខែវិច្ឆិកា"), ទំព័រ ១៥ អាចរកមើលបាននៅគេហទំព័រ http://www.soros.org/initiatives/justice/ focus/international _justice/articles_publications/publications/eccc_20091120/eccc_20091123.pdf ដែលបញ្ជាក់ថា "វាមិនសមហេតុផលឡើយក្នុងការរំពឹងថា ចៅក្រមដែលបានទទួលសំណុំរឿងត្រឹមតែពីរបីខែមុន នឹងយល់ដឹងស៊ីជម្រៅឱ្យ បានគ្រប់គ្រាន់ទៅលើអង្គហេតុដែលមានទំហំ និងវិសាលភាពបែបនេះ ដើម្បីសួរសំណួរដែលនាំទៅរកការបង្ហាញការពិតពីសាក្សី ដែលពុំមានកិច្ចសហការណ៍ឱ្យ

រឿង នៅមុនពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង នឹងមិនអាចដឹកនាំការសួរសំណួរប្រកបដោយប្រសិទ្ធភាពក្នុងលក្ខណៈដោយយកចិត្តទុកដាក់បានឡើយ។

២៩. អង្គជំនុំជម្រះសាលាដំបូងបានបន្តដំណើរការក្នុងសំណុំរឿង ០០១ ដោយយោងទៅលើកម្មវត្ថុ។ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំបញ្ជីភស្តុតាង និងបញ្ជីឈ្មោះសាក្សី នៅមុនពេលការចាប់ផ្តើមជំនុំជម្រះ[73] បានដឹកនាំការសួរសំណួរ និងបានសួរសំណួរ ឌុច ដំបូងដោយផ្អែកលើកម្មវត្ថុនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងអាចអនុវត្តបែបនេះបាន ទីមួយគឺដោយសារ ឌុច បានដឹងអំពីអង្គហេតុភាគច្រើន ដែលកំណត់នូវពិរុទ្ធភាពរបស់គាត់ និងពីព្រោះ ឌុច បានបោះបង់ចោលសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិនឆ្លើយ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានរៀបចំបន្តដំណើរការផងដែរនៅក្នុងលក្ខណៈបែបនេះ ពីព្រោះមានជនជាប់ចោទតែម្នាក់ ដីកាដំណោះស្រាយដែលមានតែ ៤៥ទំព័រ (មិនរាប់បញ្ចូលជើងទំព័រ) ទីកន្លែងឧក្រិដ្ឋកម្មមានតែមួយ និងចំនួននៃបទចោទដ៏តិចតួចប៉ុណ្ណោះ បើប្រៀបធៀបជាមួយនឹងសំណុំរឿង ០០២[74]។ ប៉ុន្តែសំណុំរឿង ០០១ នៅតែទទួលបានការរិះគន់ចំពោះការមិនបានយកចិត្តទុកដាក់ ការចម្រាញ់យកភស្តុតាងដែលមិនពាក់ព័ន្ធ និងមានភាពច្រំដែលៗ[75]។ សំណុំរឿង

---

បានពេញលេញនោះ។ ការពិនិត្យសាក្សី តម្រូវឱ្យមានការយល់ដឹងស៊ីជម្រៅទៅលើគ្រប់ទិដ្ឋភាព ទាំងអស់នៃរឿងក្តី រួមទាំងការដឹងអំពី អ្វីដែលសាក្សីដទៃទៀតបានផ្តល់ចម្លើយអំពីកត្តានីមួយៗនៃកម្មវត្ថុនៃបណ្តឹងដែលបានលើក ឡើង ចម្លើយអ្វីខ្លះផ្សេងៗទៀតដែលសាក្សីបានឆ្លើយ ចម្លើយរបស់សាក្សីស៊ីគ្នាយ៉ាងដូចម្តេចជាមួយនឹងរឿងក្តីដ៏ធំ និងការលំអៀង អ្វីខ្លះដែលសាក្សីអាចមាន។ ចៅក្រមអង្គជំនុំជម្រះពុំមានពេលវេលា ឬបុគ្គលិកជំនួយ ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើ ខ្លឹមសារលម្អិតបែបនេះនៅក្នុងរឿងក្តីដែលមានលក្ខណៈធំដូចជាសំណុំរឿង ០០២ ឡើយ"។

[73] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសដ សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈបន្ថែម ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ E5, ERN: 00250117-00250121។

[74] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/កសចស ដីកាដំណោះស្រាយ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨។

[75] The Asian International Justice Initiative's KRT Trial Monitoring Group បានរិះគន់ដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០១ ថាពុំមានការយកចិត្តទុកដាក់ និងមានការចម្រាញ់យកភស្តុតាងដែលមិនពាក់ព័ន្ធ៖ "លក្ខណៈទូទៅ នៃប្រធានបទមានន័យថា ជួនកាល ការផ្តោតនៃដំណើរការនីតិវិធីហាក់ដូចជាទៅលើធាតុផ្សំនានានៃប្រធានបទជាក់លាក់មួយ ដែលមិនទំនងជាមានផ្ទុកដោយផ្ទាល់នូវការវាយតម្លៃអំពីកម្រិតនៃពិរុទ្ធភាពរបស់ជនជាប់ចោទ។ ប្រការនេះរួមបញ្ចូលនូវការស្វែងរកឱ្យឃើញនូវលក្ខណៈខុសគ្នានៃប្រភេទនៃលទ្ធិកុម្មុយនីស្តដែលតំណាងដោយមនោគមវិជ្ជា (ដែលទំនងជានាំឱ្យមាន ការពិភាក្សាដែលមានលក្ខណៈអរូបីពេកក្នុងការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ឌុច) និងបញ្ហា បន្ទាប់បន្សំនៃលក្ខខណ្ឌគុកនៅមន្ទីរ ស២១

០០២ មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំងដោយមានជនជាប់ចោទបួននាក់។ ជនជាប់ចោទទាំងអស់ ជំទាស់ទៅនឹងបទចោទប្រឆាំងនឹងពួកគាត់។ សំណុំរឿង ០០២ មានដីកាដំណោះស្រាយដែលមាន ៤០០ទំព័រ (មិនរាប់បញ្ចូលជើងទំព័រ) ទីកន្លែងឧក្រិដ្ឋកម្មចំនួន ២០កន្លែង និងបទចោទច្រើន បើប្រៀបធៀបជាមួយនឹងសំណុំរឿង ០០១។ ប្រសិនបើនៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងប្រើនីតិវិធីជំនុំជម្រះ ដូចគ្នានៅក្នុងសំណុំរឿង ០០១ នោះនឹង**មានភវនីយហេតុយ៉ាងខ្លាំង**ថា ការជំនុំជម្រះក្នុងសំណុំរឿង ០០២ នឹងជួបប្រទះនូវបញ្ហាធ្ងន់ធ្ងរជាងការត្រឹមដែលថាមិនយកចិត្តទុកដាក់ ការចម្រាញ់យកភស្តុតាងដែលមិនពាក់ព័ន្ធ និងមានភាពច្រំដែលៗ។

៣០. ដោយសារតែអង្គជំនុំជម្រះសាលាដំបូងមានពេលវេលាកំណត់សម្រាប់ពិនិត្យសំណុំរឿង បើប្រៀបធៀបជាមួយនឹងភាគីទាំងឡាយក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវបានជួយពី

---

(ដែលហាក់ដូចជាមិនពាក់ព័ន្ធ ចំពោះវិសាលភាពដែលគាត់បានទទួលសារភាព រួចហើយថាទទួលខុសត្រូវ)"។ Michelle Staggs Kelsall et. al., *Lessons learned from the "Duch" Trial: A Comprehensive Review of the First Case Before the Extraordinary Chambers in the Courts of Cambodia*, ASIAN INTERNATIONAL JUSTICE INITIATIVE'S KRT TRIAL MONITORING GROUP, December 2009 ("Staggs")ទំព័រ ១៧។ OSJI ក៏បានរិះគន់ផងដែរចំពោះដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០១ ថាពុំមានការយកចិត្តទុកដាក់ មានភាពដដែលៗ និងការសួរសំណួរពុំមានលក្ខណៈបត់បែន ទោះបីជា OSJI បានកត់សម្គាល់ថា មានលក្ខណៈល្អប្រសើរ នៅពេលដែលការជំនុំជម្រះបានចម្រើនទៅមុខ យ៉ាងណាក៏ដោយ ៖ "ការសួរសំណួរភាគច្រើនទៅលើសាក្សីនីមួយៗ ត្រូវបាន ធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ដោយមានប្រធានអង្គជំនុំជម្រះតែងតែសួរសំណួរសាក្សី យ៉ាងច្រើន មុនពេលសួរទៅ កាន់ចៅក្រមដទៃទៀតថាតើពួកគាត់សំណួរបន្ថែមដែរឬទេ។ ដោយសារតែពេលវេលាកំណត់សម្រាប់សួរសំណួរពីភាគី ជាពិសេសពីព្រះរាជអាជ្ញា មានកម្រិតមែនទែន វាមានសារៈសំខាន់ណាស់ដែលការសួរសំណួររបស់អង្គជំនុំជម្រះបង្កើតនូវការរួម ចំណែកដ៏ច្រើនរបស់សាក្សីក្នុងការដោះស្រាយបញ្ហានៅចំពោះមុខតុលាការ។ ជាអកុសល វាមិនអាចសម្រេចបានបែបនេះជានិច្ចជាកាលឡើយ។ ការសួរសំណួររបស់តុលាការតែងតែមានលក្ខណៈមិនច្បាស់លាស់ និងច្របូកច្របល់។ ជារឿយៗ វាមានលក្ខណៈមិនច្បាស់លាស់ដែលថាមានគោលបំណងដែលពាក់ព័ន្ធ ទៅនឹងសំណួរជាជួរ។ អង្គហេតុដែលមិនស្ថិតក្នុងការ ជជែកពិភាក្សា ត្រូវបានសាក្សីជាច្រើនបញ្ជាក់ដដែលៗដោយមិនចាំបាច់។ អង្គជំនុំជម្រះតែងតែប្រកាន់ខ្ជាប់ទៅនឹងសំណួរជាជួរដែលបានរៀបចំរួចហើយ ហើយមិនខ្វល់ស្តាប់ចម្លើយរបស់សាក្សី និងសួរសំណួរដេញបន្តឡើយ នៅពេលដែលចម្លើយពុំបានឆ្លើយតបទៅនឹងសំណួរ ឬនៅពេលដែលចម្លើយបង្ហាញនូវព័ត៌មានថ្មីៗដែលមានសារៈសំខាន់"។ OSJI ការវិវឌ្ឍន៍ថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខែសីហា ឆ្នាំ២០០៩ ("OSJI ខែសីហា") ទំព័រ១៧ អាចរកមើលបាននៅគេហទំព័រ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/eccc_20090817/eccc_20090817.pdf។

សំណាក់ភាគីដែលដឹកនាំការសួរសំណួរសំខាន់ៗ។ ក.ស.ព មេធាវីការពារក្តី ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដឹងអំពីរឿងក្តីរៀងៗខ្លួនរបស់ពួកគេ ហើយវិសោធនកម្មនីតិវិធីដែលបានស្នើឡើង អនុញ្ញាតឱ្យពួកគេបង្ហាញរឿងក្តីរបស់ពួកគេ[76]។ ឧទាហរណ៍ ភាគីដែលបានកោះហៅសាក្សី នឹងដឹងថាហេតុអ្វីបានជាខ្លួនធ្វើដូច្នេះ ហើយនឹងអាចទទួលបាននូវព័ត៌មានសំខាន់ៗប្រកបដោយប្រសិទ្ធភាពជាង ប្រសិនបើភាគីសួរសំណួរសាក្សីនោះជាសំខាន់មុនគេ។ ក្នុងសំណុំរឿង ០០១ សាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសួរសំណួរមុនគេ បន្ទាប់មក ក.ស.ព ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ទៅតាមលំដាប់[77]។ ប៉ុន្តែ មានតែនៅពេលដែលមេធាវីការពារក្តីបានសួរសំណួរសាក្សីប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូងបានដឹងយ៉ាងច្បាស់ថាហេតុអ្វីបានជាសាក្សីនោះត្រូវបានកោះហៅមក។វិសោធនកម្មនីតិវិធីដែលត្រូវបានស្នើឡើង អាចឱ្យភាគីទាំងឡាយជួយដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់លំដាប់ដែលសាក្សីត្រូវបានកោះហៅឱ្យផ្តល់ភស្តុតាង ដូច្នេះភស្តុតាងត្រូវបានបង្ហាញក្នុងលក្ខណៈដែលស៊ីសង្វាក់គ្នាបំផុត និងច្បាស់លាស់បំផុត។ ប្រការនេះនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តោតទៅលើបញ្ហាសំខាន់ៗ និងបញ្ចៀសនូវបញ្ហាទាំងឡាយដែលបានប្រឈមក្នុងសំណុំរឿង ០០១[78]។

៣១. មុនកិច្ចប្រជុំពេញអង្គខែកញ្ញា ឆ្នាំ២០១០ ក.ស.ព បានសម្តែងក្តីបារម្ភស្រដៀងគ្នាដែរថា "វិធានដែលត្រូវបានធ្វើពង្រាងនាពេលថ្មីៗនេះ រំពឹងថាចៅក្រមតែងតែដឹកនាំក្នុងការសួរសំណួរជនជាប់ចោទ

[76] សូមមើល OSJI ខែវិច្ឆិកា ទំព័រ ១៥ ដែលបញ្ជាក់ថា ៖ "អយ្យការ ដែលនឹងបានបំពេញកិច្ចការទៅលើភស្តុតាងអស់រយៈពេលជាងបួនឆ្នាំ នៅពេលដែលការជំនុំជម្រះចាប់ផ្តើម គឺស្ថិតនៅក្នុងតួនាទីប្រសើរជាងក្នុងការសួរសំណួរសាក្សីប្រកបដោយប្រសិទ្ធភាពនៅក្នុងរឿងក្តីដ៏ស្មុគស្មាញបែបនេះ។ អាចជាការបំរើដល់ផលប្រយោជន៍យុត្តិធម៌ច្រើនជាង ក្នុងសំណុំរឿង ០០២ ដោយអនុញ្ញាតឱ្យអយ្យការ ដែលមានការយល់ដឹងស៊ីជម្រៅជាងទៅលើខ្លឹមសារលម្អិតនៃរឿងក្តី និងសាក្សីទាំងឡាយ ដើរតួ ជាសំខាន់នៅក្នុងការសួរសំណួរសាក្សី"។

[77] ឧទាហរណ៍ Richard Goldstone ជាសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសួរសំណួរមុនគេ បន្ទាប់មក ក.ស.ព ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ មេធាវីការពារក្តី។ រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/កសចស ប្រតិចារិក សវនាការលើកទី៧០ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ E1/74.1, ERN: 00378450-00378590។

[78] Staggs, ទំព័រ១៧។ OSJI ខែសីហា ទំព័រ១៧។

និងសាក្សីទាំងអស់...។ ជាមួយនឹងសំណុំរឿងដ៏ធំ និងស្មុគស្មាញ ការរៀបចំបែបនេះអាចពុំមែនជាការប្រើប្រាស់ពេលវេលាដ៏មានប្រសិទ្ធភាពបំផុតឡើយ ដោយត្រូវចងចាំថា អង្គជំនុំជម្រះមានពេលវេលាតិចតួចបំផុតដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើសំណុំរឿង និងចម្លើយរបស់សាក្សី"[79]។ ក.ស.ព បានផ្តល់យោបល់ថា "ទម្លាប់នៃច្បាប់ស៊ីវិលឡូ (civil law) អាចត្រូវបានរក្សាទុកដដែល ដោយចៅក្រមជំនុំជម្រះសួរសំណួរបឋមមួយឬពីរសំណួរ បន្ទាប់មកប្រគល់តួនាទីឱ្យភាគីដើម្បីសួរសំណួរសំខាន់ៗដល់សាក្សី"[80]។ ក្តីបារម្ភរបស់ ក.ស.ព បាននាំឱ្យមានការផ្លាស់ប្តូរវិធាន ៩០ ដែលបានដកយកចេញនូវឃ្លា "ក្រោយពីចៅក្រមសួរចម្លើយរួច" ចេញពីមុខឃ្លា "សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវីមានសិទ្ធិសួរជនជាប់ចោទ"។ ទោះបីជាយ៉ាងណាក៏ដោយ វិសោធនកម្មវិធានផ្ទៃក្នុងពុំបានឈានទៅដល់ការទទួលយកនូវវិធីសាស្ត្រ ដែលដឹកនាំដោយភាគីក្នុងការសួរសំណួរសាក្សីទាំងអស់ឡើយ។ វិសោធនកម្មនីតិវិធីដែលបានស្នើ ពង្រីកវិសាលភាពទៅដល់វិធីសាស្ត្រដែលដឹកនាំដោយភាគីក្នុងការសួរសំណួរសាក្សីទាំងអស់។ ប្រការនេះនឹងអាចឱ្យភាគីដែលកោះហៅសាក្សីសួរសំណួរសាក្សីនោះជាសំខាន់មុនគេ ដោយធានាថា អង្គជំនុំជម្រះសាលាដំបូងដឹងយ៉ាច្បាស់ថាហេតុអ្វីបានជាសាក្សីនោះកំពុងផ្តល់សក្ខីកម្ម មុនពេលសួរសំណួរសំខាន់ៗរបស់ខ្លួន។

## ច. វិសោធនកម្មនីតិវិធីដែលបានស្នើសុំ នឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងរក្សានូវការចាត់ចែងដំណើរការនីតិវិធី

៣២. វិសោធនកម្មនីតិវិធីដែលបានស្នើសុំ នឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងរក្សានូវការចាត់ចែងដំណើរការនីតិវិធី[81]។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូង នឹងនៅតែមានឆន្ទានុសិទ្ធិក្នុងការជ្រើស

[79] អនុស្សរណៈអន្តរការិយាល័យពី ក.ស.ព ផ្ញើរជូន Susan Lamb មន្ត្រីសម្របសម្រួលតុលាការ "សំណើសុំធ្វើវិសោធនកម្មវិធានចំនួនពីរ ដើម្បីធ្វើឱ្យនីតិវិធីជំនុំជម្រះកាន់តែមានប្រសិទ្ធភាព ដែលទាក់ទិននឹង (១) ការបង្ហាញភស្តុតាងនៅ ពេលជំនុំជម្រះ (២) ការសួរសំណួរជនជាប់ចោទ និងសាក្សីទាំងឡាយ" ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ទំព័រ ៥-៦។

[80] ដូចជើងទំព័រខាងលើ។

[81] វិធាន ៨៥ ចែងក្នុងផ្នែកដែលពាក់ព័ន្ធ ៖ "ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី"។

រើសសាក្សីពីបញ្ជីឈ្មោះដែលភាគីទាំងឡាយបានដាក់ជូន[82]។ អង្គជំនុំជម្រះសាលាដំបូង នឹងនៅតែធ្វើការសួរសំណួរដល់សាក្សី និងអាចសួរសំណួរសាក្សីនៅពេលណាក៏បាន ក្នុងអំឡុងពេលដែលគាត់កំពុងផ្តល់សក្ខីកម្ម[83]។ អង្គជំនុំជម្រះសាលាដំបូង នឹងនៅតែសម្រេចថាតើ ការផ្តល់សក្ខីកម្មរបស់សាក្សីដែលកំពុងដំណើរការនោះ អាចនាំទៅរកការពិត ដែរឬទេ[84]។ អង្គជំនុំជម្រះសាលាដំបូង នៅតែអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែម[85]។ ទោះបីជាការមិនអនុលោមតាមវិធាន ៨០ មានលក្ខណៈចាំបាច់ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុម័តយកតាមវិសោធនកម្មនីតិវិធីដែលត្រូវ បានស្នើឡើងយ៉ាងណាក៏ដោយ ប្រការនេះនឹងគ្រាន់តែបង្ហាញថា វិធានគឺជាកិច្ចការមួយកំពុងដំណើរការ ដូចគ្នាទៅនឹងវិធានស្តីពីភស្តុតាង និងនីតិវិធីរបស់តុលាការ ICC និងតុលាការមិនអចិន្ត្រៃយ៍ដទៃទៀតដែរ។ វិធានត្រូវបានកែសម្រួលឲ្យបានល្អ ហើយការសម្រួលត្រូវធ្វើឡើងដើម្បីតម្រូវកាលៈទេសៈពិសេស ប៉ុន្តែត្រូវរក្សាភាពស្មោះត្រង់ចំពោះលក្ខណៈសំខាន់នៃស្ថាប័ន និងលិខិតុបករណ៍ជាមូលដ្ឋានរបស់ស្ថាប័ន។

## IV. សំណើសុំសវនាការលើបញ្ហាដែលទាក់ទិននៅនឹងនីតិវិធីដែលបានស្នើសុំឱ្យមានការកែប្រែ

៣៣. ចាំបាច់ត្រូវមានសវនាការមួយដើម្បីលើកនូវបញ្ហានានា ទាក់ទិននឹងវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើឡើង ដើម្បីអាចឲ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់នូវទស្សនៈរបស់ភាគីទាំងអស់ និងធ្វើការសម្រេច

---

[82] វិធាន ៨០ស្ទួន(២) ចែងក្នុងផ្នែកពាក់ព័ន្ធ ៖ "នៅពេលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាការស្តាប់សាក្សី ឬ អ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឲ្យកោះហៅបុគ្គលនោះ"។

[83] វិធាន ៩១ (២) ចែងថា ៖ "ចៅក្រម អាចសួរសំណួរ ហើយសហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី ក៏ត្រូវបានអនុញ្ញាតឲ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង។ សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះសាលាដំបូង លើកលែងតែការសាកសួររបស់ចៅក្រម សហព្រះរាជអាជ្ញា និង មេធាវី"។

[84] វិធាន ៩១(៣) ចែងថា ៖ "សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថា ចម្លើយរបស់សាក្សីនោះមិនសម្តែងឲ្យឃើញការពិត។ នៅក្នុងករណីនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា តើត្រូវស្តាប់ ឬមិនត្រូវស្តាប់ចម្លើយសាក្សីនេះ"។

[85] វិធាន ៩៣(១) ចែងក្នុងផ្នែកពាក់ព័ន្ធ ៖ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។

ឲ្យបានច្បាស់លាស់ចំពោះថាតើសវនាការនឹងត្រូវបន្តយ៉ាងដូចម្តេចនៅក្នុងសំណុំរឿង ០០២។ ដំណើរការនីតិវិធីជំនុំជម្រះ ត្រូវតែសម្រេចឲ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីអាចឲ្យភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ត្រៀមរៀបចំឲ្យមានប្រសិទ្ធភាពសម្រាប់សវនាការ។ ដូច្នេះវានឹងធ្វើឲ្យមានដំណើរការសវនាការកាន់តែល្អ។ នីតិវិធីជំនុំជម្រះក្តីដែលមានលក្ខណៈច្បាស់លាស់ នឹងបញ្ចៀសនូវបញ្ហាទាំងឡាយ នៅពេលដែលសវនាការចាប់ផ្តើម។ បញ្ហាទាំងនេះ នឹងត្រៀមរួចជាស្រេចដើម្បីលើកយកមកបង្ហាញនៅពេលកិច្ចប្រជុំរៀបចំសវនាការ ដែលកំណត់កាលបរិច្ឆេទនៅចន្លោះពាក់កណ្តាលខែមីនា និងពាក់កណ្តាលខែមេសា ឆ្នាំ២០១១[86]។ ភាគីទាំងអស់ នឹងអាចលើកឡើងនូវទស្សនៈរបស់ខ្លួន ហើយអង្គជំនុំជម្រះសាលាដំបូងមានឱកាសសម្រាប់ការពិភាក្សាដែលត្រូវជូនដំណឹង មុនការចាប់ផ្តើមសវនាការ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាទាំងអស់ដែលទាក់ទិននឹងដីកាបង្គាប់ និងវិធាន ៨០ ឬក៏យ៉ាងហោចណាស់ការផ្អាកដែលត្រូវបានស្នើសុំ ត្រូវតែសម្រេចមុនកាលបរិច្ឆេទរបស់ដីកាបង្គាប់។

## V. សំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់

៣៤. វិការៈផ្នែកនីតិវិធីមានអត្ថិភាព នៅពេលដែលដីកាបង្គាប់ ដែលអនុវត្តតាមវិធាន ៨០ ផ្លាស់ប្តូរបន្ទុកស្វែងរកភស្តុតាង រំលោភលើសិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស រំលោភលើបុព្វសិទ្ធិមិនឆ្លើយប្រឆាំងខ្លួនឯង និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី។ ដីកាបង្គាប់តម្រូវឲ្យមេធាវីការពារក្តីដាក់បញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងក្នុងរយៈពេល ៣០ថ្ងៃ។ កាលបរិច្ឆេទនេះប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះ ទោសប្រកបដោយយុត្តិធម៌។ ដូច្នេះ ការផ្អាកជាបន្ទាន់ គឺមានសារៈសំខាន់ដើម្បីការពារនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់លោក អៀង សារី។ ប្រសិនបើ ការផ្អាកនោះមិនត្រូវបានផ្តល់ជូន និងប្រសិនបើពុំមានការកែប្រែចំពោះដីកាបង្គាប់នោះទេ លោក អៀង សារី នឹងបាត់បង់ពេលវេលាខ្លះ ប្រសិនបើមិនបាត់បង់ទាំងស្រុងទេ ក្នុងការដាក់បញ្ជីឈ្មោះសាក្សីបន្ថែម។ ប្រការនេះ នឹងមិនអនុញ្ញាត

---

[86] អ៊ីម៉ែលពី Susan Lamb ផ្ញើរជូនក្រុមមេធាវីការពារក្តី អៀង សារី ការទំនាក់ទំនងទៅកាន់ភាគីទាំងអស់ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ក្រុមមេធាវីការពារក្តី អៀង សារី ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

ឲ្យលោក អៀង សារី ទទួលបានសម្ភារៈ/មធ្យោបាយគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងនាំឲ្យមាននូវវិសមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីគ្នា ជាមួយ ក.ស.ព ដែលមានពេលវេលាពេញលេញសម្រាប់រៀបចំបញ្ជីឯកសារ និងបញ្ជីឈ្មោះសាក្សីរបស់ខ្លួន។ ការផ្អាកដីកាបង្គាប់ដែលអនុវត្តចំពោះក្រុមមេធាវីការពារក្ដី គឺមានសារៈសំខាន់ណាស់ រហូតដល់មានដំណោះស្រាយទៅលើបញ្ហានេះ។

## VI. សេចក្ដីសន្និដ្ឋាន

៣៥. ក.ស.ព មានបន្ទុកស្វែងរកភស្តុតាង អនុលោមតាមវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូង ទោះបីជាពុំមានចេតនាក៏ដោយ មិនគួរស្ថិតក្នុងតួនាទីមួយដែលខ្លួនក្លាយជាផ្នួបសម្រាប់ ក.ស.ព ក្នុងការបង្ហាញនូវការដាក់ទោស ដោយទទួលបន្ទុកបង្ហាញភស្តុតាងក្នុងនាម ក.ស.ព ឡើយ។ អង្គជំនុំជម្រះសាលាដំបូង ត្រូវបានបង្កើតឡើងដោយមានចៅក្រមឯករាជ្យ ដែលប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិរំពឹងថា ចៅក្រមទាំងនោះនឹងការពារយ៉ាងមុតមាំប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សជាសកល រួមទាំង សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ។ ក្រុមមេធាវីការពារក្ដីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះក្ដី ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងស្នើឲ្យអនុវត្តផ្ទុយពីដីកាបង្គាប់ និងវិធាន ៨០ រហូតដល់រឿងក្ដីទាំងមូលប្រឆាំងនឹងលោក អៀង សារី ត្រូវបានដាក់រួចរាល់ដោយ ក.ស.ព និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី។

**អាស្រ័យហេតុនេះ** ដោយផ្អែកទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្ដីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ៖

ក. ធ្វើការជំនុំជម្រះលើសំណុំរឿងលេខ ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ។

ខ. អនុវត្តផ្ទុយពីដីកាបង្គាប់ និងវិធាន ៨០ រហូតដល់រឿងក្ដីទាំងមូលប្រឆាំងនឹងលោក អៀង សារី ត្រូវបានដាក់រួចរាល់ដោយ ក.ស.ព និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី។

គ. ផ្អាកដីកាបង្គាប់ ដែលអនុវត្តចំពោះមេធាវីការពារក្ដីរហូតដល់មានដំណោះស្រាយទៅលើបញ្ហា

នេះ។ និង

ឃ. បើកសវនាការដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងក្នុងសំណើសុំនេះ។

សូមលោកសហចៅក្រមទទួលយកសំណើសុំទាំងនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**